**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៧.១.៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខណ្ឌដង្កោ នៃរាជធានីភ្នំពេញ

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ២៤៨/១៤ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី២
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខណ្ឌដង្កោ នៃរាជធានីភ្នំពេញ ក្នុងអាណត្តិទី២ ដូចមានរាយនាមខាងក្រោមៈ

| ល.រ | គោត្តនាម និងនាមខ្លួន | ថ្ងៃខែឆ្នាំកំណើត | មុខតំណែង |
|---|---|---|---|
| ១- | លោក **ម៉ឹល កុសល** | ០៨-១០-១៩៧២ | ជាប្រធានក្រុមប្រឹក្សាខណ្ឌ |
| ២- | លោក **ម៉ៃ ម៉ុន** | ១៥-០៤-១៩៥៤ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៣- | លោក **កែវ សុភា** | ០២-០៥-១៩៦៧ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |

| | | | |
|---|---|---|---|
| ៤- | លោក **ជា សារឹម** | ០៦-០៤-១៩៤៨ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៥- | លោកស្រី **ឱ ធន់សៀប** | ០១-១០-១៩៣៩ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៦- | លោក **ទ៉ាន់ ងឹម** | ១៥-០១-១៩៥៥ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៧- | លោកស្រី **សយ សុធា** | ១១-១០-១៩៥៧ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៨- | លោក **ឈុន ហេន** | ០១-០៥-១៩៤៤ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ៩- | លោក **អ៊ុក សាម៉េត** | ០១-០១-១៩៤៧ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១០- | លោក **សួន សុថា** | ០១-០១-១៩៤៦ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១១- | លោក **នុត ម៉េងលីម** | ១៤-០១-១៩៤៤ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១២- | លោក **ស៊ឹម ស៊ុំឡេង** | ០៩-១០-១៩៨១ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៣- | លោក **នោត ឿង** | ០១-០២-១៩៤៧ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៤- | លោក **ម៉ៃ សេង** | ០១-០៤-១៩៥០ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៥- | លោក **អ៊ុយ សុន** | ១២-០២-១៩៤៧ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៦- | លោក **ជាន មន្ថា** | ១០-១១-១៩៤៧ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៧- | លោក **ម៉ែន សេដ្ឋា** | ០៦-០៦-១៩៥៥ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៨- | លោក **ម៉ែន ស៊ីផុល** | ០១-០១-១៩៤២ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ |
| ១៩- | លោក **ពៅ ផាន** | ១៤-០៧-១៩៤៧ | ជាសមាជិកក្រុមប្រឹក្សាខណ្ឌ។ |

**មាត្រា ២.–**

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៣.–**

ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាខណ្ឌដង្កោ នៃរាជធានីភ្នំពេញ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។

**មាត្រា ៤.–**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ